ឈ្មោះក្រុមហ៊ុនបោះផ្សាយៈ ក្រុមហ៊ុន **គ្រេនឆ្វីន អ៊ិនធើណេសិនណាល ភីអិលស៊ី**
អក្សរកូដរបស់ក្រុមហ៊ុនបោះផ្សាយៈ ហ.ធ.អ
កាលបរិច្ឆេទនៃការបញ្ជូនៈ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៥ ម៉ោងៈ ១០ និង ៣០ នាទី

**ទម្រង់ទី៣៣-ខ : ករណីមានចំណេញ/ខាតប្រតិបត្តិការ ឬចំណេញ/ខាតសុទ្ធ ធៀបទៅនឹងពេលដូចគ្នានៃ ឆ្នាំសារពើពន្ធចុងក្រោយដែលថយចុះ ឬកើនឡើងចាប់ពី ៣០(សាមសិប) ភាគរយឡើងទៅសម្រាប់ក្រុម ហ៊ុនបោះផ្សាយ ដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០ .០០០. ០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ១៥(ដប់ប្រាំ) ភាគរយ ឡើងទៅ សម្រាប់ក្រុមហ៊ុនបោះផ្សាយ ដែលមានមូលធនភាគហ៊ុនិកសរុប ច្រើនជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ**

| | | | | |
|---|---|---|---|---|
| ១.មូលធនភាគហ៊ុនិក សរុប | ☐ តិចជាង ២០.០០០ .០០០. ០០០<br>☑ ច្រើនជាង ២០.០០០.០០០.០០០ | | | |
| ២. ប្រភេទនៃចំណេញ/ខាត | ☐ ចំណេញ/ខាត ប្រតិបត្តិការ<br>☑ ចំណេញ/ខាត សុទ្ធ | | | |
| ៣. ការពិពណ៌នាអំពីការប្រែប្រួល | ឆ្នាំសារពើពន្ធ ចុងក្រោយ | ឆ្នាំសារពើពន្ធ មុន | បរិមាណ កើន/ថយ | អត្រា កើន/ថយ (%) |
| ចំណេញ/ខាត ប្រតិបត្តិការ | | | | |
| ចំណេញ/ខាត សុទ្ធ | ១៤.១៤៧.៥០៨.០០០ រៀល | ២៩.១៤៥.៩៣៨.០០០ រៀល | ១៤.៩៩៨.៤៣០.០០០ រៀល | ៥១,៤៦ |
| ៤. មូលហេតុនៃការប្រែប្រួល | - ការធ្វើកូដកម្មទូទាំងប្រទេសពីសំណាក់សហជីពកម្មករតាមបណ្ដារោងចក្រនានា ក្នុងទាមទារតម្លើងប្រាក់ខែគោល នៅឆ្នាំ២០១៤ ។<br>- សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លើការតម្លើងប្រាក់ខែគោលសម្រាប់កម្មករនិយោជិកដែលបម្រើការងារនៅរោងចក្រកាត់ដេរ នៅឆ្នាំ២០១៤ ។<br>- កូដកម្មខុសច្បាប់ធ្វើឡើងដោយកម្មករនិយោជិក បម្រើការងារនៅក្រុមហ៊ុន គ្រេនឆ្វីន កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ ដែលរហូតដល់មានការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ | | | |
| ៥. ផលប៉ះពាល់ពីការប្រែប្រួល | - ការធ្វើកូដកម្ម បានធ្វើឲ្យខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន ត្រូវបានផ្អាកមួយរយៈពេលក្នុងកំឡុងពេលដែលមានកូដកម្មតាមបណ្ដារោងចក្រនៅទូទាំងប្រទេស។<br>- ខ្សែសង្វាក់ផលិតកម្មស្ថិតក្នុងភាពអស្ថេរ ដូចជា ការយឺតយ៉ាវក្នុងការរៀបចំវត្ថុធាតុដើមសម្រាប់ផលិត ការរៀបចំវេចខ្ចប់ និងបញ្ជូនទំនិញទៅអតិថិជន ដោយមិនអាចឆ្លើយតបនឹងតម្រូវការអតិថិជនឲ្យបានទាន់ពេលវេលា។<br>- ចំណាយរបស់ក្រុមហ៊ុនបានកើនឡើងដោយសារការតម្លើងប្រាក់ខែគោលសម្រាប់ | | | |

| | |
|---|---|
| | កម្មករនិយោជិត។<br>- ចំណាយក្រុមហ៊ុនបានកើនឡើង ដោយសារការធ្វើកូដកម្មខុសច្បាប់ពីសំណាក់កម្ម ករនិយោជិត ដែលក្នុងនោះក្រុមហ៊ុនបានចំណាយទឹកប្រាក់មួយចំនួនធំ សម្រាប់ការផ្ដល់សេវាប្រឹក្សាយោបល់ និង មេធាវី ជាដើម។ |
| ៦. វិធានការដោះស្រាយ | ក្រុមហ៊ុន ហ្រ្គេន ធ្វីន ជឿជាក់យ៉ាងមុតមាំទៅលើសេដ្ឋកិច្ច នយោបាយ និងបទប្បញ្ញត្តិនៅកម្ពុជា និងសង្ឃឹមថាមិនមានកូដកម្មធ្ងន់ធ្ងរណាមួយនាពេលអនាគតកើតឡើងដូចឆ្នាំកន្លងទៅ<br>ជាពិសេស គឺពាក់ព័ន្ធនឹងការតម្លើងប្រាក់ខែគោលសម្រាប់កម្មករនិយោជិត។ក្រុមហ៊ុន នឹងពង្រឹងទំនាក់ទំនងរឹងមាំបន្ថែមទៀត ជាមួយនិយោជិតតាមរយៈការប្រព្រឹត្តល្អជាមួយនិយោជិត ដោយអនុវត្តនូវគោលនយោបាយដូចជាការផ្ដល់ជូនប្រាក់លាភការ និងការតម្លើងតួនាទីជាដើម និងប្ដេជ្ញាថា នឹងអនុវត្តតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងរក្សាទំនាក់ទំនងដ៏ល្អជាមួយនឹងនិយោជិត។ |
| ៧. ឯកសារភ្ជាប់ | - របាយការណ៍ហិរញ្ញវត្ថុក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ ចុងក្រោយ (ប្រសិនមាន)<br>- ផ្សេងៗ |

ហត្ថលេខា និងឈ្មោះបុគ្គលិកទទួលបន្ទុក
ក្នុងការផ្ដល់ព័ត៌មាន

យឹម រស្មី